# សេចក្តីថ្លែងការណ៍រួម

# ការឃាត់ខ្លួននិងប្រើហិង្សាយ៉ាងអាក្រក់លើសារព័ត៌មាននិងសកម្មជន

# នៅតំបន់ភ្នំតាម៉ៅ

*រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២*

យើងខ្ញុំ ជាអង្គការលើកកម្ពស់សេរីភាពសារព័ត៌មាន សិទ្ធិមនុស្ស និងសង្គមស៊ីវិល ដែលមានរាយនាមដូចខាងក្រោម សូមសម្តែងការសោកស្តាយយ៉ាងខ្លាំងចំពោះការប្រើប្រាស់អំពើហិង្សា ការឃាត់ខ្លួនតាមទំនើងចិត្ត និងការបំភិតបំភ័យអ្នកសារព័ត៌មានចំនួន៥នាក់និងសកម្មជនចំនួន៤នាក់កាលពីពេលថ្មីៗនេះពីសំណាក់មន្ត្រីកងអង្គរក្សនាយករដ្ឋមន្ត្រីនៅតំបន់ព្រៃភ្នំតាម៉ៅ។

អ្នកសារព័ត៌មានចំនួន៥នាក់មកពីអង្គភាពសារព័ត៌មានឯករាជ្យ វីអូឌី(VOD)និងយុវជនខ្មែរថាវរៈចំនួន៤នាក់ត្រូវបានឃាត់ខ្លួនដោយអយុត្តិធម៌អស់រយៈពេលប្រមាណ៧ម៉ោងកាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២។ អ្នកទាំងនោះត្រូវបានឃាត់ខ្លួននៅក្នុងព្រៃភ្នំតាម៉ៅកាលពីព្រឹកថ្ងៃអង្គារ ដោយមន្ត្រីកងអង្គរក្សរបស់នាយករដ្ឋមន្ត្រី (BHQ) និងបញ្ជូនមកកាន់អធិការដ្ឋាននគរបាលស្រុកបាទី ខេត្តតាកែវ។

អាជ្ញាធរបានប្រាប់អ្នកកាសែត វីអូឌី ថាពួកគេមិនត្រូវបានអនុញ្ញាតឱ្យថតរូប វីដេអូ ឬបង្ហោះជូននៅភ្នំតាម៉ៅទេ ដោយអះអាងថារូបថតនិងវីដេអូទាំងនោះអាចត្រូវបានប្រើប្រាស់ដើម្បីផ្សព្វផ្សាយព័ត៌មានមិនពិត។ ការចោទប្រកាន់នោះមិនសមហេតុផលទ្បើយ ហើយយើងខ្ញុំមិនអាចទទួលយកការរឹតត្បិតតាមអំពើចិត្តលើអ្នកសារព័ត៌មានទ្បើយ។

យើងខ្ញុំក៏សម្តែងការសោកស្តាយផងដែរចំពោះការប្រើអំណាចដោយខុសច្បាប់របស់អាជ្ញាធរនិងការប្រើអំពើហិង្សាលើរូបរាងកាយលើអ្នកសារព័ត៌មាននិងសកម្មជន ហើយយើងអំពាវនាវឱ្យមានការស៊ើបអង្កេតដោយឥតលម្អៀងលើហេតុការណ៍នេះ ក៏ដូចជាផ្តន្ទាទោសចំពោះអាជ្ញាធរណាដែលប្រព្រឹត្តល្មើសនឹងច្បាប់ និងផ្តល់យុត្តិធម៌សម្រាប់ជនរងគ្រោះ។

អ្នកថតវីដេអូរបស់វីអូឌីម្នាក់ត្រូវបានមន្ត្រីកងអង្គរក្សទះកំផ្លៀងនៅពេលដែលគាត់បដិសេធមិនប្រគល់ទូរសព្ទដែលគាត់ប្រើដើម្បីថតនៅពេលដែលកងអង្គរក្សសួរនាំសហការីរបស់គាត់។

លោក ហ៊ី ឆាយ ជាអ្នកថតវីដេអូរបស់ វីអូឌីនិងជនរងគ្រោះដោយកងអង្គរក្សទះកំផ្លៀងបាននិយាយថា *«ខ្ញុំកំពុងដើរទៅវត្ត [ក្នុងព្រៃភ្នំតាម៉ៅ] និងឮថាសហការីត្រូវឃាត់ខ្លួន។ ខ្ញុំក៏ត្រលប់ទៅរកពួកគាត់វិញនិងដក*

*ទូរសព្ទដើម្បីថតទុកជាឯកសារ ស្រាប់តែមានអង្គរក្សម្នាក់ដើរមករកខ្ញុំ និងប្រាប់ខ្ញុំកុំឱ្យថតហើយគាត់ចង់យកទូរសព្ទពីខ្ញុំប៉ុន្តែខ្ញុំមិនឱ្យ។ គាត់ក៏ទះកំផ្លៀងខ្ញុំនិងឆក់យកទូរសព្ទពីដៃខ្ញុំ»។*

លោក ហ៊ុន វណ្ណៈ សកម្មជនខ្មែរថាវរៈក៏ត្រូវបានមន្ត្រីអង្គរក្សវាយម្តងហើយម្តងទៀតខណៈពួកគេរុញគាត់ឡើងរថយន្តក្នុងអំឡុងពេលឃាត់ខ្លួន។

លោក ហ៊ុន វណ្ណៈ បាននិយាយក្រោយពេលលោកត្រូវដោះលែងថា៖ *«ខ្ញុំបដិសេធមិនឡើងរថយន្តហើយគាត់បានដាល់មុខខ្ញុំបីដៃនិងលោតទាត់ក្បាលខ្ញុំ»។*



រូបថតចេញពីវីឌីអូបង្ហោះដោយខ្មែរថាវរៈកាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២ បង្ហាញសកម្មភាពមន្ត្រីកងអង្គរក្សក្នុងសម្លៀកបំពាក់ស៊ីវិលឃាត់ក្រុមអ្នកសារព័ត៌មានវីអូឌីនិងសកម្មជនដែលរួមមានលោក ហ៊ុន វណ្ណៈ ផងដែរ

អាជ្ញាធរបានអះអាងកាលពីថ្ងៃទី១៦ ខែសីហា ថា អ្នកទាំង៩នាក់បានចូលទៅក្នុងតំបន់ហាមឃាត់ក្នុងព្រៃភ្នំតាម៉ៅ (ជាទីតាំងដែលមានការឈូសឆាយនិងកាប់បំផ្លាញព្រៃឈើប្រមាណ១ភាគ៤នៃទំហំដីសរុបកាលពីដើមខែ)។ ប៉ុន្តែក្នុងរយៈពេលប៉ុន្មានសប្តាហ៍នេះ អ្នកសារព័ត៌មាននិងអ្នកផ្សេងទៀតអាចរាយការណ៍ ថតរូប និងថតវីដេអូដោយសេរីអំពីការកាប់បំផ្លាញព្រៃឈើ ការដាំដើមឈើឡើងវិញ និងការអភិវឌ្ឍផ្សេងៗទៀតនៅក្នុងតំបន់នេះ។ ការរឹតត្បិតទាំងនេះកើតឡើងភ្លាមៗតាមទំនើងចិត្តនិងរំលោភលើសេរីភាពសារព័ត៌មាន។

លើសពីនេះ អ្នកកាសែតទាំង៥នាក់និងសកម្មជនខ្មែរថាវរៈ៤នាក់រួមមានលោក ហ៊ុន វណ្ណៈ អ្នកស្រី ឈឿន ដារ៉ាវី កញ្ញា ឆែម ស្រីគា និងកញ្ញា សុគន្ធ តុលា ត្រូវបានដោះលែងកាលពីល្ងាចថ្ងៃអង្គារបន្ទាប់ពីអាជ្ញាធរតម្រូវឱ្យពួកគេផ្តិមមេដៃលើ «កិច្ចសន្យា»។ កិច្ចសន្យានោះបានសរសេរថា អ្នកសារព័ត៌មានបានបង្ហោះផ្សាយដោយគ្មានការអនុញ្ញាតពីអាជ្ញាធរបើទោះបីជាមិនមានច្បាប់ណាចែងពីការហាមមិនឱ្យបង្ហោះផ្សាយនៅតំបន់នោះក៏ដោយ។ យើងចាត់ទុកទង្វើនេះថាជាការបង្ខិតបង្ខំ ការយាយី និងការបំភិតបំភ័យ។

សិទ្ធិរបស់អ្នកកាសែតឯករាជ្យក្នុងការរាយការណ៍ព័ត៌មានដោយសេរីនៅក្នុងប្រទេសកម្ពុជាត្រូវតែមានការការពារជាពិសេសនៅពេលរាយការណ៍អំពីបញ្ហាផលប្រយោជន៍សាធារណៈដូចជាការកាប់បំផ្លាញព្រៃឈើនៅភ្នំតាម៉ៅអស់ជាច្រើនហិកតានាពេលថ្មីៗនេះ។ ច្បាប់ស្តីពីសារព័ត៌មានឆ្នាំ១៩៩៥ របស់កម្ពុជាដែលនៅធរមាននៅឡើយ បានហាមប្រាមចំពោះការត្រួតពិនិត្យមុនបោះពុម្ពផ្សាយ ដូចហេតុការណ៍ដែលបានកើតឡើងនៅថ្ងៃទី១៦ខែសីហានៅពេលដែលអាជ្ញាធរបានប្រាប់អ្នកកាសែតថាពួកគេមិនត្រូវបានអនុញ្ញាតឱ្យថតរូបឬថតវីដេអូនៅក្នុងតំបន់នោះឡើយដោយគ្មានការអនុម័តជាមុនឡើយ និងនៅពេលដែលមន្ត្រីអង្គរក្សរឹបអូសយកឧបករណ៍របស់ពួកគេរួមមានទូរសព្ទ កាមេរ៉ា និងដ្រូនជាដើម។

ដូចគ្នានេះដែរ អ្នកសារព័ត៌មាននិងសកម្មជន មានសិទ្ធិក្នុងការចងក្រងឯកសារនិងត្រួតពិនិត្យដោយសេរីអំពីការបំផ្លិចបំផ្លាញបរិស្ថាននិងការរំលោភសិទ្ធិ និងបញ្ចេញមតិជាសាធារណៈដែលជាសិទ្ធិត្រូវបានការពារដោយរដ្ឋធម្មនុញ្ញរបស់កម្ពុជានិងច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ។

យើងឈរដោយសាមគ្គីភាពជាមួយសហការីរបស់យើងដែលធ្វើការនៅក្នុងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនិងជាអ្នកការពារសិទ្ធិមនុស្សប្រឆាំងនឹងអំពើហិង្សាដែលប្រព្រឹត្តដោយអាជ្ញាធរ ការឃាត់ខ្លួនតាមទំនើងចិត្ត ការយាយី និងការបំភិតបំភ័យ។ យើងខ្ញុំសូមស្នើសុំដោយទទូចដល់អាជ្ញាធរជាតិឱ្យគោរពច្បាប់ស្តីពីរបបសារព័ត៌មាន រដ្ឋធម្មនុញ្ញ ព្រមទាំងច្បាប់ជាតិ និងអន្តរជាតិទាំងអស់ដែលធានាសិទ្ធិសេរីភាពនៃការបញ្ចេញមតិ និងសិទ្ធិរបស់អ្នកសារព័ត៌មាននិងអ្នកការពារសិទ្ធិមនុស្សទាំងអស់ក្នុងការចងក្រងឯកសារនិងផ្សព្វផ្សាយជាសាធារណៈនូវសកម្មភាពរបស់រដ្ឋនិងបម្រើសង្គម។

## សាវតារ

អំពើហិង្សានិងការឃាត់ខ្លួនអ្នកកាសែតវីអូឌី៥នាក់និងសកម្មជនខ្មែរថាវរៈចំនួន៤នាក់កាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២ បានកើតឡើងតែប៉ុន្មានថ្ងៃប៉ុណ្ណោះបន្ទាប់ពីព្រៃភ្នំតាម៉ៅរងការកាប់បំផ្លាញអស់ជាច្រើនហិកតាដោយបានបាត់បង់ព្រៃឈើប្រមាណ៥០០ហិកតាលើផ្ទៃដីប្រមាណ២០០០ហិកតាក្នុងរយៈពេលប្រហែលមួយសប្តាហ៍។ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បញ្ជាឱ្យដាំដើមឈើវិញនៅថ្ងៃទី៧ ខែសីហា

ដោយលុបចោលសម្បទានដែលរដ្ឋាភិបាលរបស់លោកផ្តល់ឱ្យពាណិជ្ជករមួយចំនួនរួមមានឧកញ៉ា ទ្បេង ណាវ៉ាត្រានិងឧកញ៉ា យុន សៀ។ ការលុបចោលនេះបានធ្វើឡើងបន្ទាប់ពីអត្ថបទរបស់ វីអូឌី រួមជាមួយនឹងរូបថតនិងវីដេអូថតដោយដ្រូនអំពីការកាប់បំផ្លាញព្រៃឈើយ៉ាងឆាប់រហ័ស។ អត្ថបទព័ត៌មានផ្សេងទៀតនិងរូបភាពថតដោយដ្រូននៃការឈូសឆាយបានធ្វើឱ្យសាធារណជនផ្ទុះកំហឹងនៅលើបណ្តាញសង្គមជុំវិញការកាប់បំផ្លាញព្រៃឈើនោះ។

អ្នកសារព័ត៌មានវីអូឌី៥នាក់ដែលត្រូវបានឃាត់ខ្លួនកាលពីថ្ងៃអង្គារ ពេលនោះកំពុងតាមដានបន្តអំពីស្ថានការណ៍នៅទីនោះ ដែលក្នុងនោះរួមមានទាំងការសម្ភាស ថតរូប និងថតវីដេអូដោយប្រើដ្រូនជាដើម។

សកម្មជនខ្មែរថាវរៈត្រូវបានឃាត់ខ្លួន បន្ទាប់ពីសមាជិកម្នាក់របស់ខ្លួនកំពុងផ្សាយផ្ទាល់តាមហ្វេសប៊ុកពីភ្នំតាម៉ៅ ហើយក្រុមសកម្មជននេះក៏បានដាក់ញត្តិអំពីព្រៃភ្នំតាម៉ៅទៅមន្ទីរកសិកម្មរុក្ខាប្រមាញ់និងនេសាទខេត្តតាកែវផងដែរ។ មានការបាយការណ៍ថា អាជ្ញាធរបានចាប់ផ្តើមបោះបង្គោលនៅតំបន់ដីព្រៃននោះ ដោយធ្វើឱ្យអ្នកភូមិមានការងឿងឆ្ងល់និងជំរុញឱ្យក្រុមសកម្មជនខ្មែរថាវរៈចុះទៅមើល។

សម្តេច ហ៊ុន សែន បានប្រកាសកាលពីល្ងាចថ្ងៃអង្គារថា ឥលូវនេះ កងអង្គរក្សរបស់គាត់ទទួលខុសត្រូវក្នុងការយកឈើដែលបានកាប់រួចចេញ រៀបចំដី និងដាំដើមឈើឡើងវិញនៅភ្នំតាម៉ៅ បន្ទាប់ពីរដ្ឋាភិបាលរបស់លោកកាលពីមុនបានអនុញ្ញាតឱ្យក្រុមហ៊ុនឯកជនអភិវឌ្ឍនិងឈូសឆាយផ្នែកខ្លះនៃព្រៃឈើភ្នំតាម៉ៅ។ នាយករដ្ឋមន្ត្រីក៏បានណែនាំឱ្យក្រសួងកសិកម្មរៀបចំភ្នំតាម៉ៅឡើងវិញជាតំបន់ព្រៃការពារ។

**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖**

- លោក អ៊ិត សូធឿត នាយកប្រព័ន្ធផ្សព្វផ្សាយនៃមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) លេខមានបណ្តាញ Signal លេខ (+៨៥៥) ១២៨១៩៥៤៥ (ភាសាខ្មែរនិងអង់គ្លេស)
- អ្នកស្រី ឈឿន ដារ៉ាវី សមាជិកខ្មែរថាវរៈ Signal លេខ (+៨៥៥) ១២ ២០៩ ៣១១ (ភាសាខ្មែរ)
- លោក ណុប វី នាយកប្រតិបត្តិសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJa) លេខមានបណ្តាញ Signal លេខ(+៨៥៥) ១២៥១៩២៦១ (ភាសាខ្មែរនិងអង់គ្លេស)

- លោក អំ សំអាត នាយកទទួលបន្ទុកកិច្ចការទូទៅនៃអង្គការលីកាដូ លេខមានបណ្ដាញ Signal (+៨៥៥) ១០៣២៧៧៧០ (ភាសាខ្មែរ)
- អ្នកនាង ណាលី ពីឡូក នាយិកាទទួលបន្ទុកកិច្ចការក្រៅតំបន់នៃអង្គការលីកាដូ  លេខមានបណ្ដាញ Signal (+៨៥៥) ១២២១៨៤៥៤ (ភាសាអង់គ្លេស)
- លោក ដានីញែល បាស្តាត នាយកប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិកនៃអង្គការអ្នកកាសែតគ្មានព្រំដែន តាមអ៊ីមែល dbastard@rsf.org (ភាសាអង់គ្លេស)

**សេចក្តីថ្លែងការណ៍នេះ ចូលរួមគាំទ្រដោយ៖**

1. អង្គការអាក់សិនអេដកម្ពុជា
2. វិទ្យាស្ថានតស៊ូមតិនិងគោលនយោបាយ
3. អង្គការក្រុមការងារដើម្បីដោះស្រាយទំនាស់ (ក.ដ.ទ.)
4. អង្គការអភិវឌ្ឍន៍សំលេងសហគមន៍
5. សមាគមកម្ពុជាការពារអ្នកកាសែត
6. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
7. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ
8. សមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា
9. សម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា  (CHRAC)
10. សមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា (អាដហុក)
11. វិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា
12. សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)
13. សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស (លីកាដូ)
14. សមាគមបណ្តាញយុវជនកម្ពុជា
15. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្ស (សង់ត្រាល់)
16. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរីនិងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល)
17. មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន (ម.អ.ច.ស.)
18. អង្គការយេនឌ័រនិងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC)
19. សម្ព័ន្ធអ្នកសារព័ត៌មានអន្តរជាតិ (IFJ)

20. ក្លិបអ្នកសារព័ត៌មានបរទេសនៃកម្ពុជា (OPCC)
21. អង្គការអ្នកកាសែតគ្មានព្រំដែន
22. សមាគមធាងត្នោត
23. អង្គការតម្លាភាពអន្តរជាតិកម្ពុជា
24. អង្គការទ្រទ្រង់ភូមិ
25. កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន
26. សហគមន៍ដីធ្លី ១៩៧ (កោះកុង)
27. សហគមន៍ដីធ្លីអណ្តូងត្របែក (ស្វាយរៀង)
28. សហគមន៍ដីធ្លីជីខក្រោម (កោះកុង)
29. សហគមន៍ជនជាតិភាគតិចគួយ (ព្រះវិហារ)
30. សហគមន៍ជនជាតិដើមភាគតិចឃុំប្រមេរុខេត្តព្រះវិហារ
31. សហគមន៍មានជ័យ (ស្វាយរៀង)
32. សហគមន៍ភ្នំក្រោម (សៀមរាប)
33. សហគមន៍ព្រៃឈើពេជ្រចង្វារល្អឆើត (កំពង់ឆ្នាំង)
34. សហគមន៍ដីធ្លីព្រៃពាយ (កំពត)
35. សហគមន៍សាមគ្គីចេកមាស (ស្វាយរៀង)
36. សហគមន៍សាមគ្គីរមាសហែក (ស្វាយរៀង)
37. សហគមន៍សាមគ្គីសង្កែពីរមានរិទ្ធិ (ព្រះវិហារ)
38. សហគមន៍ស្រែប្រាំង (ត្បូងឃ្មុំ)
39. សហគមន៍ធនធានព្រៃឈើស្ទឹងខ្សាច់ស (កំពង់ឆ្នាំង)
40. សហគមន៍ត្រពាំងជោ (កំពង់ស្ពឺ)